# (៣១)

# ប្រកាសស្តីពី

# នីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន

# សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល

លេខ: ១៣៩៦ សហវ.ប្រក

ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៦០ សហវ.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន
## សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៩/៤៧២ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៣៩អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលប្រកបដោយភាពទាន់ពេល តម្លាភាព និងគណនេយ្យភាព។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២

## ការបង្កើតរជ្ជទេយ្យបុរេប្រទាន និងការតែងតាំងរជ្ជទេយ្យករបុរេប្រទាន

## ផ្នែកទី១

## ការបង្កើតរជ្ជទេយ្យបុរេប្រទាន

ប្រការ៤.-

រជ្ជទេយ្យបុរេប្រទាន គឺជាចំណាយលើដំណើរការរដ្ឋបាល ដែលមានលក្ខណៈជាប្រចាំ បន្ទាន់ ដែលមិនទាមទារការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងមិនអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីធម្មតាបាន។ មុខសញ្ញាចំណាយតាមរជ្ជទេយ្យបុរេប្រទានរួមមាន÷

- ចំណាយចាំបាច់ជាប្រចាំសម្រាប់ការងាររដ្ឋបាល រួមមានជាអាទិ៍ ការទិញសម្ភារៈ និងការជួសជុល
- ចំណាយសម្រាប់សង្គ្រោះជាបន្ទាន់ពិសេស
- ចំណាយសម្រាប់ប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស
- ចំណាយសម្រាប់លាភការរបស់បុគ្គលិក
- ចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា
- ចំណាយផ្សេងៗទៀតសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។

ប្រការ៥.-

រជ្ជទេយ្យបុរេប្រទាន ត្រូវបង្កើតឡើងដោយភ្ជាប់ជាមួយនូវតារាងឧបសម្ព័ន្ធ ដែលក្នុងនោះត្រូវជ្រើសរើសយកមាតិកាសេដ្ឋកិច្ច ចំណាយតាមគណនី និងអនុគណនីនៃជំពូក៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក៦២ "អត្ថប្រយោជន៍សង្គម", ជំពូក៦៤ "បន្ទុកបុគ្គលិក", និងជំពូក៦៥ "ឧបត្ថម្ភធន" និងតាមមាតិកាកម្មវិធី។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន អាចត្រូវបានកែសម្រួលទៅតាមតម្រូវការចំណាយជាក់ស្តែងតាមការចាំបាច់។ គំរូតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

ប្រការ៦.-

កញ្ចប់ឥណទានរជ្ជទេយ្យបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាឥណទានថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គ្រប់ជំពូក គណនី អនុគណនី ដែលនៅសល់ក្រោយពីការដកឥណទានថវិកា ដែលត្រូវការសម្រាប់ការទូទាត់ត្រង់ និងឥណទានថវិកា ដែលមានក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនោះ។

ប្រការ៧.-

ទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដោយ១ភាគ៤នៃឥណទានរជ្ជទេយ្យបុរេប្រទាន។ យន្តការនៃជុំបង្វិល និងការបំពេញឡើងវិញ ត្រូវធ្វើឡើងតាមគោលការណ៍ ដូចខាងក្រោម÷

- ទឹកប្រាក់រជ្ជទេយ្យបុរេប្រទាន ដែលបានផ្តល់គ្រាដំបូងអាចមានចំនួនតិចជាង ឬស្មើនឹងទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន
- ការទូទាត់ទឹកប្រាក់រជ្ជទេយ្យបុរេប្រទានក្នុងមួយលើក ត្រូវកំណត់មិនឱ្យលើសពីទំហំទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន

- ការទូទាត់ទឹកប្រាក់រជ្ជទេយ្យបុរេប្រទាន ត្រូវបានអនុញ្ញាតឱ្យធ្វើឡើងច្រើនលើក ទៅតាមតម្រូវការជាក់ស្តែងដោយមិនកំណត់ពេលវេលា ហើយមិនត្រូវលើសឥណទានរជ្ជទេយ្យបុរេប្រទានប្រចាំឆ្នាំ ប៉ុន្តែត្រូវធានានិរន្តរភាពនៃចំណាយលើដំណើរការរដ្ឋបាល រហូតដល់ដំណាច់ឆ្នាំថវិកានីមួយៗ
- ទឹកប្រាក់រជ្ជទេយ្យបុរេប្រទាន ត្រូវបានបំពេញឡើងវិញ ក្រោយការទូទាត់លើមួយជុំបង្វិលយ៉ាងហោចណាស់ពី៦០% ទៅ៧៥% លើកលែងការទូទាត់ទាំងឡាយណា ដែលធ្វើឡើងក្រោយកាលបរិច្ឆេទនៃការបើកសាច់ប្រាក់ចុងក្រោយ ដែលកំណត់ដោយប្រកាសស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ៨._

ការបង្កើតរជ្ជទេយ្យបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ បន្ទាប់ពីទទួលបានសំណើពីនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល។

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលខុសត្រូវរៀបចំ និងធ្វើសំណើទៅក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបង្កើតរជ្ជទេយ្យបុរេប្រទាន ដោយភ្ជាប់មកជាមួយនូវសេចក្តីព្រាងប្រកាសអន្តរក្រសួង និងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានរៀងរាល់ដើមឆ្នាំថវិកានីមួយៗ។

គំរូប្រកាសអន្តរក្រសួងស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

## ផ្នែកទី២

## ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន

ប្រការ៩._

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវស្នើការតែងតាំងរជ្ជទេយ្យករបុរេប្រទាន ឬរជ្ជទេយ្យករបុរេប្រទានរង តាមការចាំបាច់ បន្ទាប់ពីមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល។

ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ។

គំរូប្រកាសអន្តរក្រសួងស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

ប្រការ១០._

រជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ឬបុគ្គលិកខាងក្រៅក្នុងករណីចាំបាច់ ដែលស្របតាមលក្ខខណ្ឌវិនិច្ឆ័យដូចខាងក្រោម÷

- ត្រូវមានចំណេះដឹង ឬបទពិសោធន៍លើការងារគណនេយ្យយ៉ាងតិច ០១ឆ្នាំ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

- ជាមនុស្សហ្មត់ចត់ សកម្ម យកចិត្តទុកដាក់នឹងការងារ មានការទទួលខុសត្រូវខ្ពស់ និងមានពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញមុខងារ
- យល់ដឹងអំពីគោលនយោបាយ ច្បាប់ នីតិវិធី និងបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ផ្នែកទី៣

## ការទទួលខុសត្រូវរបស់រជ្ជទេយ្យករបុរេប្រទាន

**ប្រការ១១.-**

រជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន ផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងជាប្រាក់កាស ចំពោះការទុកដាក់ថែរក្សាប្រាក់កាស ដែលខ្លួនបានទទួល បានចំណាយ និងការទុកដាក់ថែរក្សាលិខិតយុត្តិការ ព្រមទាំងការកាន់កាប់បញ្ជីគណនេយ្យនៃកិច្ចប្រតិបត្តិការរជ្ជទេយ្យបុរេប្រទាន។

## ជំពូកទី៣

## កិច្ចដំណើរការនៃរជ្ជទេយ្យបុរេប្រទាន

## ផ្នែកទី១

## ការដកប្រាក់រជ្ជទេយ្យបុរេប្រទាន

**ប្រការ១២.-**

រជ្ជទេយ្យករបុរេប្រទាន ត្រូវបំពេញបែបបទស្នើសុំបើកគណនីទៅគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលបន្ទាប់ពីទទួលបានការតែងតាំងរួច។

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចរៀបចំសំណើសុំបើកគណនីរជ្ជទេយ្យករបុរេប្រទាននៅធនាគារដៃគូណាមួយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ។

**ប្រការ១៣.-**

រជ្ជទេយ្យករបុរេប្រទាន ត្រូវប្រគល់ប្រកាសអន្តរក្រសួងស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងប្រកាសអន្តរក្រសួងស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាន ដោយភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ជូនគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ០១ច្បាប់ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន០១ច្បាប់ និងអគ្គនាយកដ្ឋានរតនាគារជាតិចំនួន ០១ច្បាប់។

រជ្ជទេយ្យករបុរេប្រទាន និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវតាមដានការប្រើប្រាស់ឥណទានរជ្ជទេយ្យបុរេប្រទាន។

រជ្ជទេយ្យករបុរេប្រទាន ត្រូវរាយការណ៍អំពីស្ថានភាពនៃការប្រើប្រាស់រជ្ជទេយ្យបុរេប្រទាន ជូននាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលតាមរយៈមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរក្សាទុកឥណទានជាបណ្ដោះអាសន្នលើសលាភបត្រតាមដានការប្រើប្រាស់ឥណទាន នៅតាមមាតិកាចំណាយថវិកានៃតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានដែលមានចំនួនទឹកប្រាក់ស្មើនឹងឥណទានរជ្ជទេយ្យបុរេប្រទានប្រចាំឆ្នាំ។

គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរក្សាទុកឥណទានជាបណ្ដោះអាសន្ន ដែលមានចំនួនទឹកប្រាក់ស្មើនឹង ០១ជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន។

ប្រការ១៤._

រជ្ជទេយ្យករបុរេប្រទាន ត្រូវស្នើសុំដកប្រាក់រជ្ជទេយ្យបុរេប្រទាននៅជុំបង្វិលដំបូង ទៅគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលនូវចំនួនទឹកប្រាក់ស្មើ ឬតិចជាងទឹកប្រាក់នៃជុំបង្វិល ដោយយោងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានដែលបានបង្កើត។

គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំបណ្ណស្នើសុំដកប្រាក់ពីរតនាគារជាតិ ដោយយោងតាមសំណើរបស់រជ្ជទេយ្យករបុរេប្រទាន។ បណ្ណស្នើសុំដកប្រាក់ ត្រូវមានហត្ថលេខារបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល និងហត្ថលេខារបស់គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

រជ្ជទេយ្យករបុរេប្រទាន អាចស្នើសុំដកប្រាក់រជ្ជទេយ្យបុរេប្រទានជុំដំបូងស្មើ ឬតិចជាងចំនួនទឹកប្រាក់មួយជុំបង្វិលនៃតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានឆ្នាំមុន ឬតាមសេចក្ដីព្រាងនៃតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានរបស់ឆ្នាំអនុវត្តថវិកាដោយមានហត្ថលេខារបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងករណីការបង្កើតរជ្ជទេយ្យបុរេប្រទាននៅដើមឆ្នាំថវិកាមានការយឺតយ៉ាវ។

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំសំណើទៅរតនាគារជាតិ ដើម្បីស្នើសុំផ្ដល់បុរេប្រទានដោយបញ្ចូលទៅក្នុងគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនូវចំនួនទឹកប្រាក់ ដែលត្រូវបើករជ្ជទេយ្យបុរេប្រទានក្នុងករណីដែលគណនីប្រាក់បញ្ញើនោះ ពុំមានសមតុល្យគ្រប់គ្រាន់សម្រាប់បើកផ្ដល់រជ្ជទេយ្យបុរេប្រទានក្នុងជុំទី០១។ សំណើសុំបុរេប្រទាន ត្រូវមានចុះហត្ថលេខារបស់នាយក និងគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើសំណើទៅរតនាគារជាតិ សុំទូទាត់ប្រាក់បុរេប្រទានដែលទទួលបានដោយកាត់បន្ថយពីគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោយពីមានចំណូលថវិកាពីឧបត្ថម្ភធន ឬពីចំណូលផ្ទាល់ចូលក្នុងគណនីប្រាក់បញ្ញើ។

## ផ្នែកទី២

## ការចំណាយ និងការទូទាត់ប្រាក់រជ្ជទេយ្យបុរេប្រទាន

ប្រការ១៥._

ជាគោលការណ៍មុននឹងចំណាយប្រាក់ រជ្ជទេយ្យករបុរេប្រទាន ត្រូវស្នើសុំគោលការណ៍ចំណាយទៅនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ការចំណាយប្រាក់ ត្រូវមានសក្ខីប័ត្របញ្ជាក់ត្រឹមត្រូវដោយតម្រូវឱ្យអ្នកទទួលប្រាក់ចុះហត្ថលេខា។

ចំណាយរដ្ឋទេយ្យបុរេប្រទាននឹងមិនអាចអនុវត្តបានឡើយ ប្រសិនបើគ្មានការអនុញ្ញាតពីនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល។

ប្រការ១៦._

រាល់បណ្ណចំណាយ ត្រូវមានភ្ជាប់ជាមួយនូវគោលការណ៍ចំណាយ វិក្កយប័ត្រ ឬសក្ខីប័ត្រចំណាយ ដែលរដ្ឋទេយ្យករបុរេប្រទានបានធ្វើការទូទាត់ ដោយមានការបញ្ជាក់ទទួលស្គាល់ពីនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល។

ប្រការ១៧._

ចំនួនទឹកប្រាក់សម្រាប់មួយបណ្ណចំណាយ ត្រូវបានកំណត់ត្រឹមចំនួន ៥លានរៀលជាអតិបរមា លើកលែងតែមុខសញ្ញាចំណាយដែលមានរបបកំណត់ច្បាស់លាស់។

ចំពោះមុខសញ្ញាចំណាយដែលមិនមានរបបកំណត់ និងមានលក្ខណៈចាំបាច់ បន្ទាន់ (លើកលែងចំណាយដំណើរការរដ្ឋបាល) ដែលតម្រូវការចំណាយមានទំហំទឹកប្រាក់ធំជាង៥លានរៀល អាចត្រូវបានអនុញ្ញាតក្នុងក្របខ័ណ្ឌឥណទានរដ្ឋទេយ្យបុរេប្រទាន ដូចខាងក្រោម÷

- លើសពីចំនួន ៥លានរៀលដល់ ២០លានរៀល នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលអាចចាត់ចែងអនុវត្តភ្លាម និងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលបន្ទាប់
- លើសពីចំនួន ២០លានរៀល ដល់ ១០០លានរៀល នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវសុំការសម្រេចយល់ព្រមពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីចាត់ចែងអនុវត្ត និងរាយការណ៍ជូនក្រុមប្រឹក្សាភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលបន្ទាប់។

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធានានូវតម្លាភាព និងគណនេយ្យភាពក្នុងការអនុវត្តនីតិវិធីចំណាយនេះ។

មិនអនុញ្ញាតឱ្យមានការបំបែកបណ្ណចំណាយទៅតាមទីកន្លែង, គោលដៅចំណាយ, ពេលវេលា, ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលបំណងគេចវេះការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

ប្រការ១៨._

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបោះផ្សាយអាណត្តិនិយ័តកម្មលើមូលដ្ឋាននៃលិខិតយុត្តិការចំណាយត្រឹមត្រូវ និងគ្រប់គ្រាន់ ដោយភ្ជាប់ជាមួយនូវដីកាអមបញ្ចេញអាណត្តិបើកប្រាក់ចំនួន០១ច្បាប់ និងដីកាអមលិខិតយុត្តិការចំនួន០១ច្បាប់ រួចផ្ញើទៅអភិបាលហិរញ្ញវត្ថុ ដើម្បីផ្តល់ទិដ្ឋាការទូទាត់រដ្ឋទេយ្យបុរេប្រទាន។ ក្នុងករណីដែលពិនិត្យឃើញថាលិខិតយុត្តិការចំណាយមួយចំនួនពុំមានលក្ខណៈត្រឹមត្រូវ នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបញ្ជូនលិខិតយុត្តិការចំណាយទាំងនោះទៅរដ្ឋទេយ្យករបុរេប្រទានវិញ ដើម្បីធ្វើការកែតម្រូវ។

ប្រការ១៩._

អភិបាលហិរញ្ញវត្ថុ ត្រូវបញ្ជូនអាណត្តិនិយ័តកម្ម និងលិខិតយុត្តិការចំណាយត្រឡប់ទៅនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលវិញដើម្បីកែតម្រូវ ក្នុងករណីពិនិត្យឃើញថាលិខិតយុត្តិការចំណាយពុំមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ។ ក្នុងករណីពិនិត្យឃើញថាគ្មានបញ្ហា អភិបាលហិរញ្ញវត្ថុត្រូវផ្តល់ទិដ្ឋាការ និង [illegible]

និងលិខិតយុត្តិការ [illegible]
អនុវត្តមុខការបន្ត។

ប្រការ២០._

គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបញ្ជូនលិខិតយុត្តិការចំណាយទាំងនោះត្រឡប់ទៅនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាលវិញតាមរយៈមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដោយមានការបញ្ជាក់អំពីចំណុចខ្វះខាត ក្នុងករណីដែលលិខិតយុត្តិការចំណាយទាំងនោះពុំទាន់គ្រប់គ្រាន់ និងត្រឹមត្រូវសម្រាប់ជាមូលដ្ឋានចុះកិច្ចបញ្ជិកាគណនេយ្យ។ ក្រោយពីកែតម្រូវ ឬបំពេញបន្ថែមរួច នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្ញើលិខិតយុត្តិការទាំងនោះជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុសារជាថ្មីសម្រាប់ការកែតម្រូវ និងបញ្ជូនមកគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលវិញ។

គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្តល់ការទូទាត់អាណត្តិនិយ័តកម្ម និងចាត់ទុកជាចំណាយថវិកា ព្រមទាំងធ្វើការកត់ត្រាចំនួនទឹកប្រាក់នោះទៅក្នុងគណនីរជ្ជទេយ្យករបុរេប្រទាន ក្នុងករណីពិនិត្យឃើញថាលិខិតយុត្តិការចំណាយទាំងនោះមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ។

ប្រការ២១._

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចបោះផ្សាយអាណត្តិនិយ័តកម្មក្នុងទឹកប្រាក់តិចជាង ឬស្មើនឹងទឹកប្រាក់មួយដុំបង្គិលនៃរជ្ជទេយ្យបុរេប្រទាន។

ការបោះផ្សាយអាណត្តិនិយ័តកម្ម ដើម្បីទូទាត់រជ្ជទេយ្យបុរេប្រទាន ដែលមានចំនួនទឹកប្រាក់ស្មើនឹងទឹកប្រាក់មួយដុំបង្គិលនៃរជ្ជទេយ្យបុរេប្រទានសម្រាប់តែគណនី ឬអនុគណនីណាមួយនឹងមិនត្រូវបានអនុញ្ញាតឡើយ។

ប្រការ២២._

ការអនុវត្តចំណាយតាមរជ្ជទេយ្យបុរេប្រទាន ត្រូវប្រព្រឹត្តទៅតាមវដ្តនៃរជ្ជទេយ្យបុរេប្រទាន ដែលចែកចេញជា ០៤ដំណាក់កាល ដូចខាងក្រោម÷

១. ដកប្រាក់រជ្ជទេយ្យបុរេប្រទាន

២. ចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន

៣. រៀបចំលិខិតយុត្តិការដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម

៤. ទូទាត់រជ្ជទេយ្យបុរេប្រទាន។

កិច្ចដំណើរការចំណាយតាមវដ្តនៃរជ្ជទេយ្យបុរេប្រទាន ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

គំនូសបំព្រួញអំពីវដ្តនៃរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ដូចខាងក្រោម÷




## ផ្នែកទី៣
## វិធានការអនុវត្តនាពេលដំណាច់ឆ្នាំ

ប្រការ២៣._

ការទូទាត់ជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទានក្នុងឆ្នាំថវិកា ត្រូវធ្វើឡើងយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំថវិកា។

សាច់ប្រាក់រជ្ជទេយ្យបុរេប្រទាន ដែលនៅសល់នាពេលដំណាច់ឆ្នាំ ត្រូវបង់ចូលគណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារជាតិ។

ក្នុងករណីដែលមានតម្រូវការចាំបាច់ គ្រឹះស្ថានសាធារណៈរដ្ឋបាល អាចរក្សាទុកមួយផ្នែកនៃសាច់ប្រាក់រជ្ជទេយ្យបុរេប្រទាន ដែលនៅសល់នាពេលដំណាច់ឆ្នាំសម្រាប់ការប្រើប្រាស់ជារជ្ជទេយ្យបុរេប្រទានក្នុងជុំបង្វិលទី១ នៃរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំថវិកាបន្ទាប់។ ទឹកប្រាក់នេះ នឹងជាកម្មវត្ថុនៃការដកចេញពីកញ្ចប់សាច់ប្រាក់រជ្ជទេយ្យបុរេប្រទានជុំទី១ នៃឆ្នាំថវិកាបន្ទាប់។

## ជំពូកទី៤
## គណនេយ្យរដ្ឋទេយ្យបុរេប្រទាន
### កិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទានរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

**ប្រការ២៤.-**

កិច្ចប្រតិបត្តិការរដ្ឋទេយ្យបុរេប្រទាន ត្រូវអនុវត្តដោយរដ្ឋទេយ្យករបុរេប្រទាន និងតាមដានគ្រប់គ្រងដោយគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។ រដ្ឋទេយ្យករបុរេប្រទាន ត្រូវកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទាន។

**ប្រការ២៥.-**

កិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទាន នឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន និងគណនេយ្យរដ្ឋទេយ្យចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ជំពូកទី៥
## ការត្រួតពិនិត្យ និងសវនកម្ម

**ប្រការ២៦.-**

ការគ្រប់គ្រងរដ្ឋទេយ្យបុរេប្រទាន គឺជាកម្មវត្ថុនៃការត្រួតពិនិត្យវាយតម្លៃ ដោយសវនករផ្ទៃក្នុងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ២៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស
  "ដើម្បីសហការ អនុវត្ត"
- ដូចប្រការ២៧
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

លេខ ០០៤ ចប.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមប្រកាសលេខ ១៣៩០ សហវ ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦
របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបញ្ជូនមក៖

-ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

"ដើម្បីជូនជ្រាប"

-ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

"ដើម្បីជ្រាប និងមុខការ"

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧

ត.ប រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គលេខាធិការរង

ចាន់ ហេង

ឧបសម្ព័ន្ធទី១.១

(គំរូតារាងឧបសម្ព័ន្ធភ្ជាប់តាមប្រកាសលេខ......ចុះថ្ងៃទី................ ស្ដីពីនីតិវិធីចំណាយតាមរបបបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័ន.....

គ្រឹះស្ថានសាធារណៈរដ្ឋបាល...

តារាងឧបសម្ព័ន្ធរបបបុរេប្រទានថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ.....

របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល......

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលស្នើបើក | ឥណទានរបបបុរេប្រទាន | ឥណទានទូទាត់រួច | ឥណទាន៩០ថ្ងៃបន្ថែមរបបបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២-៣ | ៥= ៣/៤ថ្ងៃ | ៦= ៣/២ |
| | | | សរុបរួម | | | | | | |
| 60 | | | ការទិញ | | | | | | |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | | | | | | |
| | | 60011 | | | | | | | |
| | ..... | ..... | | | | | | | |
| 61 | | | សេវាកម្ម | | | | | | |
| | ..... | ..... | | | | | | | |
| | ..... | ..... | | | | | | | |
| | ..... | ..... | | | | | | | |
| 64 | | | បន្ទុកបុគ្គលិក (ក្រៅពីប្រាក់បៀវត្ស...) | | | | | | |
| | ..... | ..... | | | | | | | |
| | ..... | ..... | | | | | | | |
| | ..... | ..... | | | | | | | |
| 62 | | | អត្ថប្រយោជន៍សង្គម | | | | | | |
| | ..... | ..... | | | | | | | |
| | ..... | ..... | | | | | | | |
| | ..... | ..... | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | |
| | ..... | ..... | | | | | | | |
| | ..... | ..... | | | | | | | |
| | ..... | ..... | | | | | | | |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ...
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ...
គណនេយ្យករប្រចាំគ្រឹះស្ថាន
សាធារណៈរដ្ឋបាល...

ថ្ងៃទី..... ខែ....... ឆ្នាំ....
រដ្ឋទេយ្យករបុរេប្រទាន

បានឃើញនិងឯកភាព
ថ្ងៃទី..... ខែ....... ឆ្នាំ....
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី..... ខែ....... ឆ្នាំ....
អគ្គនាយក/នាយកគ្រឹះស្ថាន
សាធារណៈរដ្ឋបាល...

ឧបសម្ព័ន្ធទី១.២

(គំរូតារាងឧបសម្ព័ន្ធភ្ជាប់តាមប្រកាសលេខ......ចុះថ្ងៃទី..............ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័ន.....
គ្រឹះស្ថានសាធារណៈរដ្ឋបាល...

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធីឆ្នាំ.....
របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល.....

| ជំពូក | គណនី | អនុគណនី | បរិយាយ | កម្មវិធីទី.... | | | | | | អនុកម្មវិធី.... | | | | | | ចង្កោមសកម្មភាពទី... | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ក្រោយ | ឥណទានទទួលបន្ទុករជ្ជទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ក្រោយ | ឥណទានទទួលបន្ទុករជ្ជទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ក្រោយ | ឥណទានទទួលបន្ទុករជ្ជទេយ្យបុរេប្រទាន | ភាគរយ |
| | | | | ១ | ២ | ៣ | ៤= ២-៣ | ៥= ៣/៤ជុំ | ៦= ៣/២ | ១ | ២ | ៣ | ៤= ២-៣ | ៥= ៣/៤ជុំ | ៦= ៣/២ | ១ | ២ | ៣ | ៤= ២-៣ | ៥= ៣/៤ជុំ | ៦= ៣/២ |
| | | | សរុបរួម | | | | | | | | | | | | | | | | | | |
| 60 | | | ការទិញ | | | | | | | | | | | | | | | | | | |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | | | | | | | | | | | | | | | | | | |
| | | 60011 | | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 61 | | | សេវាកម្ម | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 64 | | | បន្ទុកបុគ្គលិក (ប្រាក់បៀវត្ស...) | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 62 | | | អត្ថប្រយោជន៍សង្គម | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ......ឆ្នាំ....
អគ្គនាយក/នាយកគ្រឹះស្ថាន
សាធារណៈរដ្ឋបាល...

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.......ឆ្នាំ....
គណនេយ្យករប្រចាំគ្រឹះស្ថាន
សាធារណៈរដ្ឋបាល...

ថ្ងៃទី.....ខែ.......ឆ្នាំ..
រជ្ជទេយ្យករបុរេប្រទាន

ឧបសម្ព័ន្ធទី២

(គំរូប្រកាសអន្តរក្រសួងស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទានទៅគ្រឹះស្ថានសាធារណៈរដ្ឋបាល)

រាជធានីភ្នំពេញ, ថ្ងៃទី........ខែ.........ឆ្នាំ....

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរជ្ជទេយ្យបុរេប្រទាន
## នៅគ្រឹះស្ថានសាធារណៈរដ្ឋបាល.....

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ លក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ..............ចុះថ្ងៃទី.....ខែ.......ឆ្នាំ......ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ......
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ.......អនក្រ.បក ចុះថ្ងៃទី.......ខែ.......ឆ្នាំ.....ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ........(ក្រសួង/ ស្ថាប័ន/ អង្គភាព)
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីរបបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ២០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៩៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៩៨ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការបង្កើតបន្ថែមគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៩៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបង្កើតបន្ថែមគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ.......ចុះថ្ងៃទី.....ខែ......ឆ្នាំ២០១៦ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង/ស្ថាប័ន/អង្គភាព.....

**សម្រេច**

<u>ប្រការ១.</u>-

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក៦២ "អត្ថប្រយោជន៍សង្គម", ជំពូក៦៤ "បន្ទុកបុគ្គលិក", ជំពូក៦៥ "ឧបត្ថម្ភធន" នៅគ្រឹះស្ថានសាធារណៈរដ្ឋបាល...............សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ....ចុះថ្ងៃទី.....ខែ......ឆ្នាំ២០១៦ ស្តីពីការចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

<u>ប្រការ២.</u>-

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

<u>ប្រការ៣.</u>-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

<u>ប្រការ៤.</u>-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន/ប្រធាននាយកដ្ឋាន/ប្រធានអង្គភាពទទួលបន្ទុករដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួង/ស្ថាប័ន/អង្គភាព........... ព្រមទាំងនាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល........ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួង/ប្រធានស្ថាប័ន/ប្រធានអង្គភាព...

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ឧបសម្ព័ន្ធទី៣

(គំរូប្រកាសអន្តរក្រសួងស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាននៅគ្រឹះស្ថានសាធារណៈរដ្ឋបាល)

*រាជធានីភ្នំពេញ ថ្ងៃទី....... ខែ........ ឆ្នាំ.....*

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

**ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន**

**នៅគ្រឹះស្ថានសាធារណៈរដ្ឋបាល.........................**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ លក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ....... អនក្រ.បក ចុះថ្ងៃទី....... ខែ....... ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ........(ក្រសួង/ស្ថាប័ន/អង្គភាព)
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញប្រកាសលេខ ០០៤ សហវ.ប.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៥៩៨ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការបង្កើតបន្ថែមគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៨៩៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការបង្កើតបន្ថែមគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ......ចុះថ្ងៃទី......ខែ......ឆ្នាំ២០១៦ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង/ស្ថាប័ន/អង្គភាព.....

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំង÷

- លោក/លោកស្រី............................(ឈ្មោះ)...............................(មុខងារ) ជារដ្ឋទេយ្យករបុរេប្រទាន នៅគ្រឹះស្ថានសាធារណៈរដ្ឋបាល......
- លោក/លោកស្រី............................(ឈ្មោះ)...............................(មុខងារ) ជារដ្ឋទេយ្យករបុរេប្រទានរង នៅគ្រឹះស្ថានសាធារណៈរដ្ឋបាល......

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន/ប្រធាននាយកដ្ឋាន/ប្រធានអង្គភាពទទួលបន្ទុករដ្ឋបាលនិងហិរញ្ញវត្ថុរបស់ក្រសួង/ស្ថាប័ន/អង្គភាព....... នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល.... ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួង/ប្រធានស្ថាប័ន/ប្រធានអង្គភាព.....

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ